តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia



# ករណីសិក្សា

# ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម នៅប្រទេសកម្ពុជា

«ការណែនាំអំពីការអនុវត្តជាក់ស្តែង»

© អង្គការតម្លាភាពកម្ពុជា ២០១៨

**អង្គការតម្លាភាពកម្ពុជា**
ផ្ទះលេខ ១៣ ផ្លូវលេខ ៥៥៤ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក,
១២១៥១, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រក្នុងប្រទេស: **www.ticambodia.org**
គេហទំព័រនៅការិយាល័យកណ្តាល: **www.transparency.org**

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

អង្គការតម្លាភាពកម្ពុជាគឺជាសាខាក្នុងប្រទេសមួយដែលមានការទទួលស្គាល់ពេញលេញរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញជាច្រើនដែលប្តេជ្ញាបង្កើតសង្គមកម្ពុជាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ចាប់ពីពេលនោះមកអង្គការនេះបានបង្កើតជាស្ថាប័នដ៏រឹងមាំមួយដែលប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាពតម្លាភាព និងគណនេយ្យភាពក្នុងប្រទេស។

យើងធ្វើការជាមួយបុគ្គល និងស្ថាប័នជាច្រើននៅគ្រប់កម្រិតដូចជារដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព លើកកម្ពស់សុចរិតភាព និងប្រឆាំងអំពើពុករលួយ។

ឯកសារនេះត្រូវបានរៀបរៀងឡើងក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប ប្រទេសស៊ុយអែត និងប្រទេសស្វីស។ រាល់ខ្លឹមសារនៅក្នុងឯកសារនេះពុំឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ប្រទេសស៊ុយអែត ឬប្រទេសស្វីសឡើយ។

©រូបថតក្របមុខ៖ **Artisans Angkor**
©២០១៨ អង្គការតម្លាភាពកម្ពុជា។ រក្សាសិទ្ធគ្រប់យ៉ាង។

ស៊ុយអែត Sverige

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

# មាតិកា

## បញ្ជីពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| BIP | Business Integrity Programme | កម្មវិធីពង្រឹងសុចរិតភាពធុរកិច្ច |
| CSR | Corporate Social Responsibility | ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម |
| RBC | Responsible Business Conduct | ការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវ |
| SDGs | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព |
| TI Cambodia | Transparency International Cambodia | អង្គការតម្លាភាពកម្ពុជា |

## ១. សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

សហគ្រាសធុនតូច និងមធ្យមជាធាតុផ្សំដ៏ចាំបាច់មួយសម្រាប់សេដ្ឋកិច្ចប្រទេសកម្ពុជា។ នៅឆ្នាំ ២០១៧ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ាន់ស្មានថាមានក្រុមហ៊ុនខ្នាតតូច និងមធ្យមប្រមាណ ១៥២.៣៣២ កំពុងប្រតិបត្តិការនៅប្រទេសកម្ពុជា។[១] សហគ្រាសធុនតូច និងមធ្យមត្រូវបានកំណត់ទៅតាមចំនួនបុគ្គលិក និងទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន៖

| | ចំនួនបុគ្គលិក | ទ្រព្យសកម្មហិរញ្ញវត្ថុដោយមិនរាប់បញ្ចូលដីធ្លី (គិតជាដុល្លាអាមេរិក) |
|---|---|---|
| មីក្រូ | តិចជាង ១០នាក់ | តិចជាង ៥០,០០០ |
| ខ្នាតតូច | ១១ - ៥០នាក់ | ៥០,០០០ - ២៥០,០០០ |
| ខ្នាតមធ្យម | ៥១ - ១០០នាក់ | ២៥០,០០០ - ៥០០,០០០ |
| ខ្នាតធំ | លើសពី ១០០នាក់ | លើសពី ៥០០,០០០ |

*ប្រភពពី៖* *ធនាគារ ADB និងអនុគណៈកម្មការសហគ្រាសធុនតូចនិងមធ្យមរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៥ និង២០០៧*

ខណៈពេលដែលសហគ្រាសធុនតូច និងមធ្យមមានប្រតិបត្តិការលើគ្រប់វិស័យ ក្រសួងរ៉ែ និងថាមពលបានបែងចែកសហគ្រាសទាំងនេះជា៣ផ្នែក៖

១) វិស័យផលិតកម្ម រាប់បញ្ចូលដំណើរការកសិកម្ម កម្មន្តសាល និងរ៉ែ

២) វិស័យសេវាកម្ម និង

៣) វិស័យពាណិជ្ជកម្ម រាប់បញ្ចូលទាំងលក់ដុំ និងលក់រាយ។[២]




សហគ្រាសធុនតូច និងមធ្យមភាគច្រើន ផ្តោតសំខាន់ទៅលើការបណ្តាក់ទុនក្នុងស្រុក ស្របពេលដែលក្រុមហ៊ុនធំៗតម្រង់ទិសទៅ រកវិនិយោគទុនបរទេស។ ក្នុងឆ្នាំ២០០៩ សហគ្រាសធុនតូច និងមធ្យមមានចំនួន ៩៨,៥% ខណៈដែលឧស្សាហកម្មធំៗមាន ចំនួន១,៥% នៃអ្នកផលិតទាំងអស់។[៣] សម្រាប់សហគ្រាសធុនតូច និងមធ្យមដែល បានចុះបញ្ជីភាគច្រើនគឺ ស្ថិតនៅក្នុងវិស័យ ម្ហូបអាហារភេសជ្ជៈ និងថ្នាំជក់ហើយបន្ទាប់ មកគឺ រោងចក្រផលិតរ៉ែដែលមិនមែនជា លោហធាតុ (លើកលែងតែប្រេងឥន្ធនៈ និង ធ្យូងថ្ម វាយនភ័ណ្ឌឧស្សាហកម្មសម្លៀក បំពាក់ និងស្បែកសត្វរោងចក្រផលិតដែក ឧស្សាហកម្មគ្រឿងម៉ាស៊ីននិងឧបករណ៍។[៤]

ដោយសារតែ ទិដ្ឋភាពច្បាប់សម្រាប់ធ្វើអាជីវ កម្មនៅកម្ពុជា មានការផ្លាស់ប្តូរយ៉ាងឆាប់ រហ័សសហគ្រាសធុនតូច និងមធ្យមជាច្រើន កំពុងស្ថិតក្នុងដំណាក់កាលអនុលោមឲ្យ ស្របតាមច្បាប់ដូចជាការចុះបញ្ជីពាណិជ្ជកម្ម ពន្ធ និងច្បាប់ការងារ។ សហគ្រាសខ្នាតតូច និងមធ្យមកំពុងព្យាយាមស្វែងយល់ពីកាតព្វ កិច្ចរបស់ពួកគេដោយសិក្សាពីច្បាប់ និងយន្ត ការមួយចំនួនដែលគេអាចប្រើក្នុងការធ្វើឲ្យ អាជីវកម្មកាន់តែមានអនុលោមភាព។ អាជីវកម្មជាច្រើនព្រួយបារម្ភថា ការអនុវត្តមិន ស្មើភាពនៃបទប្បញ្ញត្តិថ្មីនឹងបង្កើតឱ្យមានការ ប្រកួតប្រជែងមិនស្មើភាពគ្នាដល់សហគ្រាស ខ្នាតតូច និងមធ្យមដោយហេតុថាអាជីវកម្ម ដែលអនុលោមទៅតាមច្បាប់នឹងបង្កើនតម្លៃ លក់ខណៈដែល អាជីវកម្មមិនស្របច្បាប់ រក្សាតម្លៃដដែល។ ក្រុមហ៊ុនខ្លះបារម្ភថាការ អនុលោមតាមច្បាប់នឹងបន្ថែមការចំណាយ ទៅលើអាជីវកម្មរបស់ពួកគេ។ ជាញឹកញាប់ សហគ្រាសធុនតូច និងមធ្យមយល់ឃើញ ថា ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម (CSR) និងការធ្វើអាជីវកម្មប្រកបដោយ ការទទួលខុសត្រូវ (RBC) ជាការចំណាយ ដ៏ច្រើនដែលសាកសមចំពោះតែអាជីវកម្ម ដែលជោគជ័យប៉ុណ្ណោះ។ ករណីសិក្សានេះ នឹងចែករំលែកនូវគម្រូនៃការអនុវត្តទំនួល ខុសត្រូវសង្គមរបស់សាជីវកម្ម និងការធ្វើ អាជីវកម្មប្រកបដោយការទទួលខុសត្រូវ របស់សហគ្រាសខ្នាតតូច និងមធ្យម និង ក្រុមហ៊ុនធំៗមួយចំនួនដែលពួកគេអនុវត្ត បានជោគជ័យ។

## ២. អ្វីទៅជា ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម និងការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវ?

ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម (CSR) គឺជារបៀបគ្រប់គ្រងមួយដែលក្រុមហ៊ុនដាក់បញ្ចូលបញ្ហាសង្គម និងបរិស្ថានទៅក្នុងប្រតិបត្តិការអាជីវកម្ម និងអន្តរកម្មរបស់ពួកគេជាមួយភាគីពាក់ព័ន្ធ។ CSR អាចត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយដែលជួយក្រុមហ៊ុនសម្រេចបាននូវតុល្យភាពនៃការចាំបាច់ខាងសង្គម សេដ្ឋកិច្ច និងបរិស្ថាន ឬលើកកម្ពស់មូលដ្ឋានត្រីគុណ។មានភាពខុសគ្នារវាង CSR និងសកម្មភាពសប្បុរសធម៌ ឬការបរិច្ចាគសប្បុរសធម៌ ដោយសារ CSR ត្រូវបានបង្កើតឲ្យទៅជាផ្នែកមួយនៃគោលនយោបាយរបស់ក្រុមហ៊ុន និងរបៀបប្រកបអាជីវកម្មរបស់គេ។ ឯការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវ (RBC) តម្រូវឲ្យគោរពតាមច្បាប់ទាំងអស់ជាពិសេសច្បាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ការការពារបរិស្ថាន ទំនាក់ទំនងការងារ និងគណនេយ្យភាពហិរញ្ញវត្ថុ សូម្បីតែនៅទីកន្លែងដែលច្បាប់នេះមិនត្រូវបានអនុវត្តយ៉ាងតឹងរឹងក៏ដោយ។ វាក៏ឆ្លើយតបទៅនឹងការរំពឹងទុករបស់សង្គមដែលមិនចែងក្នុងច្បាប់ដូចជានៅកន្លែងធ្វើការឬសហគមន៍មូលដ្ឋាន។ ជារឿយៗទិដ្ឋភាពចុងក្រោយនេះត្រូវបានសំដៅថាជា CSR។[៩] CSR និង RBC ផ្សារភ្ជាប់យ៉ាងជិតស្និតគ្នា ពីព្រោះស្របពេលដែល RBC ផ្តោតសំខាន់លើអនុលោមភាពតាមច្បាប់ CSR អាចផ្តោតបន្ថែមលើបទដ្ឋានដើម្បីបង្កើនមូលដ្ឋានត្រីគុណរបស់ពួកគេ។ ឧទាហរណ៍ ក្រុមហ៊ុនអាចសម្លឹងមើលគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) ដើម្បីត្រួសត្រាយកម្មវិធី CSR របស់ពួកគេ។ ពួកគេក៏អាចរកមើលឧបករណ៍ជាក់លាក់របស់ឧស្សាហកម្ម ដើម្បីជាការណែនាំដល់កម្មវិធី CSR របស់ពួកគេ ឧទាហរណ៍អង្គការពលកម្មអន្តរជាតិផ្តល់នូវបទដ្ឋានផលិតសម្លៀកបំពាក់តាមរយៈកម្មវិធីរោងចក្រកាន់តែប្រសើរ។



## ៣. សុចរិតភាពធុរកិច្ច និងទំនួលខុសត្រូវសង្គម

សុចរិតភាពធុរកិច្ច គឺជាធាតុផ្សំមួយដ៏ចាំបាច់សម្រាប់កម្មវិធី CSR ឬដើម្បីជួយក្រុមហ៊ុនលើកកម្ពស់កម្មវិធី RBC របស់ពួកគេ។ ការប្តេជ្ញាចិត្តរបស់សហគ្រាសក្នុងការប្រឆាំងអំពើពុករលួយ និងបង្កើនសុចរិតភាពត្រូវបានដាក់បញ្ចូលទៅក្នុងការអនុវត្ត CSR ឬ RBC ដើម្បីរក្សាបាននូវរចនាសម្ព័ន្ធអភិបាលកិច្ច និងប្រព័ន្ធខ្លាំងក្លាមួយដែលអាចរកមើលបង្ការ និងកាត់បន្ថយអំពើពុករលួយ។ តម្លាភាពនៅក្នុងការប្រព្រឹត្តរបស់ក្រុមហ៊ុនមួយ គឺមានសារៈសំខាន់ណាស់សម្រាប់ធ្វើឲ្យប្រសើរឡើងនូវឥទ្ធិពលមានលើសង្គមសហគមន៍ និងបរិស្ថាន។ ទាក់ទងទៅនឹង RBC ការអនុលោមតាមច្បាប់ជាពិសេសច្បាប់ប្រឆាំងអំពើពុករលួយ និងបទដ្ឋានអន្តរជាតិទាមទារឲ្យក្រុមហ៊ុនរក្សានូវកម្រិតសុចរិតភាពខ្ពស់ ហើយក្រុមហ៊ុនក៏ត្រូវបានតម្រូវឲ្យមានតម្លាភាពក្នុងប្រតិបត្តិការអាជីវកម្មរបស់គេ។ អង្គការតម្លាភាពកម្ពុជា (TI Cambodia) មានទស្សនៈថាការមាន និងរក្សាឲ្យបាននូវការអនុលោមទៅតាមច្បាប់ និងអនុវត្តប្រព័ន្ធគ្រប់គ្រងប្រឆាំងការសូកប៉ាន់មានសារៈសំខាន់ដើម្បីជានានូវភាពជោគជ័យនៃកម្មវិធី CSR និង RBC របស់ក្រុមហ៊ុន។ កម្មវិធីពង្រឹងសុចរិតភាពធុរកិច្ច (Business Integrity Programme) របស់អង្គការតម្លាភាពកម្ពុជាកំពុងលើកកម្ពស់គោលការណ៍តម្លាភាពគណនេយ្យភាព និងសុចរិតភាពនៅក្នុងវិស័យឯកជនដែលជាមធ្យោបាយមួយសម្រាប់ក្រុមហ៊ុនក្នុងការពង្រឹងកម្មវិធី CSR និង RBC របស់ពួកគេ។

## ៤. ទំនួលខុសត្រូវសង្គមសម្រាប់សហគ្រាសធុនតូច និងមធ្យម

គោលបំណងមួយនៃករណីសិក្សានេះ គឺដើម្បីបង្ហាញអំពីរបៀបដែល CSR និង RBC អាចត្រូវបានអនុវត្តនៅគ្រប់ទំហំនៃស្ថាប័ន ទាំងតូច មធ្យម ឬធំ ហើយវាក៏អនុវត្តចំពោះគ្រប់វិស័យផងដែរ។ នៅកម្ពុជាមានបុគ្គលិកជាង ៥០% កំពុងធ្វើការឲ្យសហគ្រាសធុនតូច និងមធ្យម[៦]ហើយដោយសារសហគ្រាសធុនតូច និងមធ្យមផ្តល់ទំហំការងារដ៏ច្រើននេះវាជាការចាំបាច់ណាស់សម្រាប់សហគ្រាសទាំងនេះរក្សាគោលនយោបាយ CSR ឬ RBC នៅក្នុងក្រុមហ៊ុនរបស់ពួកគេ ដើម្បីបង្កើតបរិយាកាសការងារប្រសើរជាងមុន។ ជាទូទៅ គេយល់ថា CSR ឬ RBC តម្រូវឲ្យមានការវិនិយោគច្រើនដើម្បីឲ្យគេទទួលស្គាល់ និងមានប្រសិទ្ធិភាព។ ក្រុមហ៊ុនដែលបានគូសបញ្ជាក់នៅក្នុងករណីសិក្សានេះបង្ហាញថាតាមរយៈការផ្លាស់ប្តូរគោលនយោបាយផ្ទៃក្នុងរបស់ក្រុមហ៊ុន និងវិធីដែលពួកគេធ្វើអាជីវកម្ម ក្រុមហ៊ុនអាចកសាង CSR និង RBC ហើយក្លាយជាអាជីវកម្មដែលប្រសើរឡើង និងមានចីរភាព។ ទោះបីជាមានកម្មវិធីមួយចំនួនត្រូវចំណាយច្រើន យើងក៏នឹងបង្ហាញពីកម្មវិធីដែលចំណាយទាប និងផ្តល់អត្ថប្រយោជន៍យូរអង្វែងដល់ក្រុមហ៊ុនផ្សេងៗ។

# ៥. សាវតាររបស់ក្រុមហ៊ុន

### ក្រុមហ៊ុន Artisans Angkor ឬសិប្បករអង្គរ

ក្រុមហ៊ុនមួយនៅកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៩០ ដើម្បីជួយប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមជនបទឲ្យមានការងារធ្វើនៅក្បែរស្រុកកំណើតរបស់ពួកគេ។ ក្រុមហ៊ុននេះមានរោងជាងចំនួន ៤៨កន្លែង ហើយស្ថិតនៅ១២ តំបន់ផ្សេងៗគ្នាក្នុងខេត្តសៀមរាប។ ក្រុមហ៊ុនសិប្បករអង្គរបានផ្តល់ការងារដល់បុគ្គលិកលើសពី ១.១០០នាក់ ដែលរាប់បញ្ចូល ៨០០នាក់ ជាសិប្បករ។

### ក្រុមហ៊ុន អេមរុាយស៍

ក្រុមហ៊ុនផលិតអង្ករមួយនៅប្រទេសកម្ពុជាដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១១។ ប្រមាណ ៩០% នៃអង្ករ គឺសម្រាប់នាំចេញ និង ១០% គឺសម្រាប់លក់ក្នុងស្រុក។ ក្រុមហ៊ុនអេមរុាយស៍មានរោងចក្រ ៥ កន្លែងដែលស្ថិតនៅ ខេត្តបាត់ដំបងខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ ហើយមានបុគ្គលិកពេញម៉ោងចំនួន ២០០នាក់ និងក្រៅម៉ោងចំនួន ៨០នាក់។

### ក្រុមហ៊ុន Golden SMEs

ក្រុមហ៊ុន Golden SMEs បាននឹងកំពុងប្រតិបត្តិអាជីវកម្មលើផ្នែកសាលាអន្តរជាតិ ដែលហៅថា អាយដៀ ស៊ស នៅខេត្តព្រះសីហនុ។ ក្រុមហ៊ុននេះក៏មានគម្រោងដំណើរការអាជីវកម្មខាងផ្នែកកែច្នៃម្ហូបអាហារ និងសិប្បកម្ម។ សព្វថ្ងៃមានបុគ្គលិកប្រមាណ ៦០នាក់ កំពុងបម្រើការនៅទីនោះ ហើយក្រុមហ៊ុននេះបើកដំណើរការអាជីវកម្មបាន ៥ឆ្នាំ ហើយ គិតពីថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៣។

## ក្រុមហ៊ុន ម្រុំធម្មជាតិ SPLE

ក្រុមហ៊ុនម្រុំធម្មជាតិ SPLE ត្រូវបានបង្កើតឡើងនៅខេត្តសៀមរាប នៅឆ្នាំ ២០១២។ ក្រុមហ៊ុននេះផលិតម្រុំ ដែលរួមមានម្រុំជាតែ និងជាថ្នាំគ្រាប់ និងមានបុគ្គលិកប្រតិបត្តិការ ៥ ទៅ ៦នាក់ និង កសិករផលិតម្រុំចំនួន ៣៣ គ្រួសារស្ថិតនៅឃុំធម្មជាតិរុនតាឯក។

## ក្រុមហ៊ុន ហូមហ្វូតឌីលីវើរី

ក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ត្រូវបានបង្កើតឡើងដោយ លោក រិច ចំរើន និងលោកស្រី ជុំ ចន្ទសុភា នៅដើមឆ្នាំ ២០១៧។ ក្រុមហ៊ុន ហូមហ្វូតឌីលីវើរីផ្តល់សេវាម្ហូបអាហារ និងដឹកជញ្ជូនម្ហូបអាហារសរីរាង្គទៅដល់អតិថិជន។ ក្រុមហ៊ុននេះក៏បានផ្តួចផ្តើមបង្កើតផ្សារសរីរាង្គមួយ ហៅថាផ្សារអាហារធម្មជាតិ។

## ហាងអាហារ Eleven One Kitchen

ហាងអាហារ Eleven One Kitchen ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៤ ដោយ លោកស្រី ស្រ៊ុន សុខលីម ដែលមានទីតាំងស្ថិតនៅម្តុំទួលទំពូង និងបានបើកសាខាមួយកន្លែងទៀត។ ហាងនេះមានបុគ្គលិកប្រមាណ ៤០នាក់ នៅទីតាំងទាំងពីរ ហើយ៩០% មិនប្រើប្រាស់ផ្លាស្ទិក។

## សហគ្រាស លាងឡេង

សហគ្រាសលាងឡេង គឺជាក្រុមហ៊ុនផលិត និងផ្គត់ផ្គង់ផលិតផល ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកខ្មេះ ទឹកម្ទេស ទឹកសៀង ទឹកប្រេងខ្យង និងប្រេងឆា។ សហគ្រាសនេះត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ ហើយមានរោងចក្រពីរ ដែលមួយគឺសម្រាប់ផលិត និងមួយទៀតគឺសម្រាប់វេចខ្ចប់។ ក្រុមហ៊ុននេះមានបុគ្គលិក ៤៨នាក់ ហើយកំពុងនឹងរៀបចំឡើងផ្សារមូលបត្រកម្ពុជា។

## ៦. ហេតុអ្វីក្រុមហ៊ុនចាំបាច់អនុវត្តទំនួលខុសត្រូវសង្គម និងការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវ?

កត្តាជម្រុញក្រុមហ៊ុនក្នុងការអនុវត្តកម្មវិធីទំនួលខុសត្រូវសង្គមមានភាពខុសគ្នាពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត។ ក្រុមហ៊ុនខ្លះអាចកំពុងស្វែងរកការទទួលស្គាល់ ឬការវិនិយោគបន្ថែមហើយក្រុមហ៊ុនខ្លះទៀតមើលឃើញពីអត្ថប្រយោជន៍ ក្នុងការវិនិយោគលើ បុគ្គលិក បរិស្ថាន ឬគុណភាពនៃក្រុមហ៊ុនរបស់ពួកគេ។ កត្តាមួយដ៏សំខាន់គឺមកពីភាពដឹកនាំឬចក្ខុវិស័យរបស់ក្រុមហ៊ុន។ ចំពោះក្រុមហ៊ុនសិប្បករអង្គរមូលហេតុនៃការអនុវត្តកម្មវិធី CSR ដល់បុគ្គលិកគឺដើម្បីបំពេញបន្ថែមជាមួយនឹងចក្ខុវិស័យដែលនឹងផ្តល់ការងារមួយដែលមានប្រាក់ខែសមរម្យ និងលក្ខខណ្ឌការងារល្អប្រសើរដល់ប្រជាពលរដ្ឋខ្មែររស់នៅតាមជនបទ។[៨] បេសកកម្មរបស់ក្រុមហ៊ុនសិប្បករអង្គរបានបញ្ជាក់ឲ្យឃើញពីគោលបំណងរបស់ពួកគេយ៉ាងច្បាស់ថា "...ពួកយើងជឿជាក់ថាការបញ្ជូនប្រពៃណីដល់ប្រជាជនរបស់យើង និងការអភិវឌ្ឍទេពកោសល្យរបស់ពួកគេនឹងផ្តល់អំណាចដល់ពួកគេដើម្បីបង្កើតឱកាស សម្រាប់ជីវិតកាន់តែប្រសើរ។[៩] " ចំណែកឯបេសកកម្មរបស់ក្រុមហ៊ុនអេមរុរាយស៍ គឺដើម្បីជួយសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រឹមឆ្នាំ២០៣០។[១០] ចំណូលចិត្តរបស់ម្ចាស់ក្រុមហ៊ុន Golden SMEs ទៅលើសកម្មភាពសង្គមលើកទឹកចិត្តឲ្យក្រុមហ៊ុនមានគោលការណ៍ CSR។ ជាងនេះទៅទៀត គាត់យល់ឃើញថា ដើម្បីរក្សាទុកនូវបុគ្គលិកល្អៗការផ្តល់បរិយាកាសការងារល្អមួយនិងការលើកទឹកចិត្តមួយចំនួនឲ្យបុគ្គលិកគឺជាការចាំបាច់ណាស់។[១១] ម្ចាស់សហគ្រាសលាងឡេង អនុវត្តកម្មវិធី CSR ពីព្រោះនេះគឺជាចំណូលចិត្តរបស់គាត់ហើយគាត់ប្តេជ្ញាចិត្តក្នុងការអនុវត្ត

កម្មវិធី CSR ក្នុងក្រុមហ៊ុនរបស់គាត់។[១២] ចំពោះប្រធានផ្នែក ចីវភាពនៅរោងចក្រកាត់ដេរលោក Jack Van Dokkum បានមានប្រសាសន៍ថាឆន្ទៈចូលរួមក្នុងសកម្មភាព CSR ក៏ចេញមកពីម្ចាស់ក្រុមហ៊ុនផ្ទាល់ផងដែរដើម្បីបង្កើតអាជីវកម្មឲ្យល្អប្រសើរដោយកែលម្អគុណភាពបរិយាកាសការងារ។[១៣] រីឯម្ចាស់ក្រុមហ៊ុន ម្រុំធម្មជាតិ SPLE បារម្ភពីសុខភាពរបស់អតិថិជន ហើយក៏មានបំណងធ្វើឲ្យសេដ្ឋកិច្ចក្នុងស្រុកល្អប្រសើរផងដែរ។[១៤] បេសកកម្មរបស់ក្រុមហ៊ុន SPLE ក៏បានសម្តែងឲ្យឃើញពីការប្តេជ្ញាចិត្តរបស់គេថា៖ "ប្រទេសរបស់យើងផលិតផលរបស់យើង និងសុខភាពរបស់អ្នកគឺមានសារៈសំខាន់ណាស់ហើយពួកយើងព្យាយាមធ្វើអ្វីគ្រប់បែបយ៉ាងដែលអាចទៅរួច ដើម្បីធានាថាអ្នកទទួលបានអត្ថប្រយោជន៍ដល់សុខភាពខ្ពស់ពីគុណភាពផលិតផលរបស់យើងដែលធ្វើឡើងនៅប្រទេសយើងទាំងអស់គ្នា។[១៥]" យោងទៅតាមម្ចាស់ហាងអាហារ Eleven One Kitchen រាល់អាជីវកម្មត្រូវមានគរុកោសល្យរបស់ខ្លួន ហើយសម្រាប់អាជីវកម្មរបស់គាត់ គឺបានផ្តល់ការយកចិត្តទុកដាក់លើផលប៉ះពាល់ទៅដល់បរិស្ថាននិងសុខភាពអតិថិជន។[១៦] ក្នុងនាមជាអាជីវកម្មដែលទើបនឹងបង្កើតថ្មីក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ចាប់ផ្តើមជាមួយនឹងបេសកកម្មរបស់ខ្លួនដែលថា ការធ្វើវិភាគទានសង្គមនឹងជាអាទិភាពចម្បងនៅពេលដែលប្រាក់ចំណេញជាអាទិភាពទីពីរ។[១៧]

## ៧. ការវិនិយោគលើបុគ្គលិក

ខណៈដែលម៉ូឌែល CSR និង RBC បាននឹងកំពុងតែវិវឌ្ឍអាជីវកម្មបានចាប់ផ្តើមមើលទៅលើមធ្យោបាយ ដើម្បីកែលម្អជីវិតប្រចាំថ្ងៃនៃការងាររបស់បុគ្គលិក និងក្នុងរយៈពេលវែង។ កម្មវិធីលើកកម្ពស់សុខុមាលភាពបុគ្គលិកមួយចំនួនបានធ្វើឡើងច្រើនជាងតម្រូវការដែលចែងក្នុងក្រមការងារកម្ពុជាទៅទៀតហើយត្រូវបានជម្រុញឲ្យធ្វើបែបនេះដើម្បីរក្សាបុគ្គលិកសកម្ម និងមានទឹកចិត្តធ្វើការងារខ្ពស់។ មធ្យោបាយមួយក្នុងចំណោមវិធីជាច្រើនគឺផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក។ ការបណ្តុះបណ្តាលផ្នែកសុខភាព និងលំហាត់ប្រាណដល់បុគ្គលិកត្រូវបានប្រើប្រាស់ក្នុងរោងចក្រកាត់ដេរ និងនៅសិប្បករអង្គរដើម្បីបង្កើនសុខភាពរបស់បុគ្គលិក។ បុគ្គលិកសិប្បករអង្គរបានទទួលការបណ្តុះបណ្តាលស្តីពីយូហ្គា និងបច្ចេកទេសដទៃទៀត ដើម្បីជួយកាត់បន្ថយការចុករោយដែលអាចនឹងកើតមានឡើងពីការធ្វើការនៅក្នុងរោងជាងច្រើនម៉ោង។ ជាងនេះទៅទៀតមេដឹកនាំរោងជាងនីមួយៗត្រូវបានបណ្តុះបណ្តាលលើជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។[១៨] វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈគឺជាគោលបំណងរបស់សិប្បករអង្គរតាំងពីយូរយារណាស់មកហើយ ប៉ុន្តែការបណ្តុះបណ្តាលលើផ្នែកសុខភាពបានធ្វើការងារថែមទៀតដើម្បីលើកកម្ពស់សុខុមាលភាពបុគ្គលិក។[១៩] រោងចក្រកាត់ដេរបានណែនាំការបណ្តុះបណ្តាលអំពីវិធីរកមើលនិងការពារជម្ងឺដែលអាចកើតឡើងមកលើសុខភាព និងអាហារូបត្ថម្ភ និងបានផ្តល់វគ្គសិក្សាអក្ខរកម្មមុននិងក្រោយម៉ោងធ្វើការ។[២០] ក្រុមហ៊ុន Golden SMEs ផ្តល់វគ្គបណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំដល់បុគ្គលិក ដើម្បីជួយបង្កើនជំនាញដឹកនាំរបស់ពួកគេ។[២១] ក្រុមហ៊ុនម្រុំធម្មជាតិ SPLE និងហាងអាហារ Eleven One Kitchen ផ្តល់វគ្គបណ្តុះបណ្តាលពីអនាម័យដល់បុគ្គលិក។[២២] បន្ថែមពីលើនេះក្រុមហ៊ុន ក៏បានលើកកម្ពស់សុខុមាលភាពបុគ្គលិក ដោយបានផ្តល់នូវអាហារសុខភាពនៅកន្លែងធ្វើការដោយចំណាយតិច ឬមិនចាំបាច់ចំណាយសម្រាប់បុគ្គលិក។ ក្រុមហ៊ុន Golden SMEs និងរោងចក្រកាត់ដេរបានផ្តល់ជូនអាហារថ្ងៃត្រង់ឥតគិតថ្លៃដល់បុគ្គលិកទាំងអស់ដែលចំណាយទាំងនេះរ៉ាប់រងដោយម្ចាស់ក្រុមហ៊ុនផ្ទាល់។[២៣] សិប្បករអង្គរក៏បានផ្តល់ជូនបុគ្គលិកនូវអាហារថ្ងៃត្រង់ជាមួយតម្លៃទាបបំផុតគឺ ១២០០រៀលក្នុងមួយពេល។[២៤] ក្រុមហ៊ុនម្រុំធម្មជាតិ SPLE បានជួលផ្ទះសម្រាប់បុគ្គលិកប្រតិបត្តិការរស់នៅនិងផ្តល់ឲ្យពួកគេនូវបាយថ្ងៃត្រង់ឥតគិតថ្លៃ។[២៥] ក្រុមហ៊ុនហូមហ្វូតឌីលីវើរីផ្តល់ឲ្យបុគ្គលិករបស់គេចំនួន៨នាក់ នូវអាហារសរីរាង្គនិងទឹកសម្រាប់ពេលថ្ងៃត្រង់។[២៦]

ច្បាប់ការងាររបស់កម្ពុជាបានតម្រូវឲ្យក្រុមហ៊ុនផ្តល់នូវកន្លែងធ្វើការល្អមួយដល់បុគ្គលិករួមទាំងផ្តល់គ្រូពេទ្យ ដែលចំណាយនេះនឹងរ៉ាប់រងដោយក្រុមហ៊ុន។[២៧] ក្រុមហ៊ុនមួយចំនួនជ្រើសរើសបង្កើនទំនួលខុសត្រូវរបស់គេទៅលើសុខភាពនិងសុខុមាលភាពរបស់បុគ្គលិក។ សិប្បករអង្គរបានផ្តល់ការពិនិត្យសុខភាពឥតគិតថ្លៃរួមមានការពិនិត្យជម្ងឺ

របេង និងភ្នែក។ វ៉ែនតាត្រូវបានកាត់ជូនដល់បុគ្គលិកកម្មករដែលមានភ្នែកមើលមិនសូវច្បាស់។ រីឯរោងចក្រកាត់ដេរវិញក៏បានផ្ដល់មួកសុវត្ថិភាពឥតគិតថ្លៃដល់បុគ្គលិកផងដែរ។[២៨]

ចំពោះក្រុមហ៊ុនអេមរុរាយស៍ការបណ្ដាក់ទុនគឺផ្ដោតទៅលើកសិករដែលក្រុមហ៊ុនទិញស្រូវពីពួកគេ។ ក្រុមហ៊ុន អេមរុរាយស៍ មានគំនិតផ្ដួចផ្ដើមមួយហៅថា "អង្ករសរីរាង្គ ដើម្បីចីរភាព" នៅឆ្នាំ ២០១៤ ដោយផ្ដល់វគ្គបណ្ដុះបណ្ដាលដល់កសិករដើម្បីធ្វើឲ្យពួកគេក្លាយជាដៃគូអាជីវកម្មជាជាងគ្រាន់តែជាអ្នកផ្គត់ផ្គង់។ ក្រុមហ៊ុន អេមរុរាយស៍ ស្វែងរកទីផ្សារឲ្យពួកគេ ដូច្នេះកសិករមិនចាំបាច់ខ្វល់ខ្វាយបន្តទៀតទេថាគេនឹងអាចលក់អង្ករនៅកន្លែងណា។ ថ្មីៗនេះមានប្រមាណ ១០,០០០កសិករបានចូលរួមក្នុងគម្រោងនេះ។ ក្រុមហ៊ុន អេមរុរាយស៍ក៏បានផ្ដល់វគ្គបណ្ដុះបណ្ដាលដល់កសិករអំពីការគ្រប់គ្រងហិរញ្ញវត្ថុ និងបច្ចេកទេសកសិកម្ម។ ក្រុមហ៊ុនអេមរុរាយស៍ជួយកសិករបើកគណនីធនាគារ និងបណ្ដុះបណ្ដាលពួកគេឲ្យចេះកត់ត្រា និងគ្រប់គ្រងហិរញ្ញវត្ថុរបស់គេ។[២៩]

## ៨. សកម្មភាពបរិស្ថាន

គោលបំណងចម្បងរបស់ហាងអាហារ Eleven One Kitchen គឺដើម្បីធ្វើឲ្យបរិស្ថានល្អប្រសើរ ដូច្នេះក្រុមហ៊ុនតែងតែស្វែងរកមធ្យោបាយថ្មីៗ ដើម្បីកែលម្អផលប៉ះពាល់បរិស្ថាន។ ភោជនីយដ្ឋានបានប្តូរទៅការវេចខ្ចប់លក្ខណៈជីវម៉ាស សម្រាប់ចំណីអាហារខ្ចប់ និងប្រើប្រាស់បំពង់បឺតឫស្សីជាជាងប្លាស្ទិក។ ពួកគេលើកទឹកចិត្តអ្នកផ្គត់ផ្គង់អាចកាត់បន្ថយប្លាស្ទិចដោយមិនវេចខ្ចប់ទំនិញរាយហើយ បុគ្គលិកត្រូវបានលើកទឹកចិត្តអោយយកថង់ទៅប្រើឡើងវិញ ពេលទិញទំនិញនៅផ្សារ។ បុគ្គលិកក៏ត្រូវបានបណ្តុះបណ្តាលលើការអនុវត្តល្អៗ ទាក់ទងនឹងការកែច្នៃ និងការបំបែកសារធាតុកែច្នៃផ្សេងគ្នា ព្រមទាំងអនាម័យការរៀបចំម្ហូបអាហារផងដែរ។[៣០] ម្ហូបអាហាររបស់ហាង Eleven One Kitchen មិនមានប៊ីចេង ហើយផលិតផលប្រើប្រាស់ជាច្រើនយកមកផ្ទាល់ពីភូមិដែលបុគ្គលិករស់នៅ និងស្គាល់ច្បាស់ពីប្រភពរបស់វា។[៣១] សហគ្រាសលាងឡេង កំពុងនឹងធ្វើការជាមួយអង្គការ UNIDO ដើម្បីស្វែងរកពីវិធីដែលក្រុមហ៊ុនអាចកាត់បន្ថយកាកសំណល់ ជួយសន្សំថាមពល ទឹក និងអគ្គិសនី។ ក្នុងដំណើរការផលិត សហគ្រាសបានព្យាយាមបម្លែងកាកសំណល់ទៅជាផលិតផលដែលប្រើបានផ្សេងទៀតហើយបានទទួលវិញ្ញាបនបត្របរិស្ថានសម្រាប់សកម្មភាពបរិស្ថានជាច្រើនដូចជាការដឹកនាំឲ្យមានសកម្មភាពរើសសម្រាមជាដើម។[៣២] ក្រុមហ៊ុន ហូមហ្វូតឌីលីវើរី យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបរិស្ថានដោយកាត់បន្ថយការប្រើប្រាស់ផ្លាស្ទិក។ ក្រុមហ៊ុនដែលទើបបង្កើតថ្មីនេះបានប្រើប្រាស់កែវ ក្រដាស និងស្លឹកឈូ និងដាក់ទំនិញក្នុងកន្ត្រកឈើសម្រាប់វេចខ្ចប់អាហារជាជាងប្រើថង់ផ្លាស្ទិក។ ពួកគេក៏ធ្លាប់ពិសោធប្រើប្រាស់ម៉ូតូអាគុយសម្រាប់ដឹកជញ្ជូនផងដែរ ប៉ុន្តែវាមិនមានចីរភាពសម្រាប់ពេលបច្ចុប្បន្ន។ នៅថ្ងៃខាងមុខ ក្រុមហ៊ុន ហូមហ្វូតឌីលីវើរី គ្រោងផ្តល់អាហារកញ្ចប់ដែលអាចជួយកាត់បន្ថយកាកសំណល់ចំណីអាហារ។[៣៣]



Photo Supplied by Leang Leng

ក្នុងនាមជាអ្នកផលិត ផលិតផលកសិកម្ម ក្រុមហ៊ុនអេមរុាយស៍ទទួលស្គាល់ពីផលប៉ះពាល់បរិស្ថាន និងព្យាយាមកាត់បន្ថយបញ្ហានេះ ដោយផ្តល់ឲ្យកសិករនូវគ្រាប់ពូជសរីរាង្គឥតគិតថ្លៃ ព្រមទាំងជីសរីរាង្គដែលធ្វើមកពីកាកសំណល់សត្វ ដែលមិនបំផ្លាញដី។ លើសពីនេះទៅទៀត ក្រុមហ៊ុនអេមរុាយស៍ លើកទឹកចិត្តកសិករមិនឲ្យបោះអង្កាមចូលទៅក្នុងដីដាំដុះ ដែលនេះនឹងធានាបាននូវស្ថេរភាពនៃជីវចម្រុះ និងជួយកាត់បន្ថយផលប៉ះពាល់បរិស្ថាន។[៣៤]

## ៩. សុចរិតភាព និងទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម

សុចរិតភាពត្រូវបានចាត់ទុកថាជាកត្តាសំខាន់ចំពោះដំណើរការនៃ CSR និង RBC របស់ក្រុមហ៊ុន ព្រោះវារួមបញ្ចូលអនុលោមភាពតាមច្បាប់ និងការប្តេជ្ញាចិត្តក្នុងការប្រឆាំងអំពើពុករលួយ។ យោងទៅតាម លោក Jack van Dokkum សុចរិតភាព និងតម្លាភាពគឺជាសសរស្តម្ភសំខាន់ពីរនៅក្នុងកម្មវិធី CSR របស់ពួកគេ។ ដោយសាររោងចក្រនេះមានបំណងលើកកម្ពស់ក្រុមហ៊ុនរបស់ខ្លួន ការរក្សាឲ្យបាននូវតម្លាភាពមានសារៈសំខាន់ណាស់សម្រាប់ប្រតិបត្តិការអាជីវកម្ម។[៣៥]

## ១០. សកម្មភាពទំនួលខុសត្រូវសង្គមនៅក្នុងសហគមន៍

បន្ថែមពីលើការវិនិយោគទៅលើបុគ្គលិក ផលប៉ះពាល់បរិស្ថាន និងសុចរិតភាព ការធ្វើសកម្មភាពសង្គមក៏បានចូលរួមមួយចំណែកផងដែរ ។ សកម្មភាពបន្ថែមទាំងនេះតែងតែបង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ឬចំណាប់អារម្មណ៍នៅក្នុងសហគមន៍ដែលអាជីវកម្មរបស់ខ្លួនដំណើរការ។ សិប្បករអង្គរដឹកនាំឲ្យមានកម្មវិធីបរិច្ចាគឈាម ប្រមូលសំរាម និងដាំដើមឈើនៅក្នុងសហគមន៍មូលដ្ឋាន។[៣៦] ក្រុមហ៊ុន Golden SMEs ក៏បានដឹកនាំឲ្យមានការសម្អាតឆ្នេរ និងការបរិច្ចាគឈាម។[៣៧] ក្រុមហ៊ុនហូមហ្វូតឌីលីវើរី អនុញ្ញាតឲ្យអាជីវកម្មក្នុងស្រុក និងសហគ្រាសសង្គមមួយចំនួន លក់ផលិតផលរបស់គេក្នុងហាងខ្លួន ហើយក៏បានផ្តល់ម្ហូបអាហារឲ្យអង្គការផ្ទះបាយកុមារ២ដងក្នុង១ឆ្នាំ ដើម្បីឲ្យក្មេងៗនៅទីនោះបានបរិភោគអាហារសុខភាព។[៣៨] សហគ្រាស លាង ឡេង មានភាពសកម្មក្នុងសហគមន៍ជាខ្លាំងក្នុងការបង្កើតឲ្យមានសកម្មភាពសម្អាតបរិស្ថាន ការបរិច្ចាគផលិតផលរបស់គេដល់សហគមន៍ដែលខ្សត់ខ្សោយ និងគាំទ្រនិស្សិតឲ្យមានចំណេះដឹងកាន់តែច្រើនអំពីផលិតកម្មរបស់សហគ្រាស និងផ្តល់អាហារូបករណ៍ទៅក្រៅប្រទេសមួយចំនួន។[៣៩] ក្រុមហ៊ុន អេមរុាយស៍បានវិភាគទានថ្លៃចំណាយខ្លះ ដើម្បីសង្គ្រោះអាជីវកម្មមួយចំនួន អំឡុងគ្រោះទឹកជំនន់ សាងសង់បណ្ណាល័យ និងផ្តល់សៀវភៅដល់សិស្សានុសិស្ស។[៤០]

## ១១. ភក្តាប្រឈម និងថ្លៃចំណាយ

សម្រាប់សហគ្រាសធុនតូច និងមធ្យម បញ្ហាប្រឈមធំបំផុតមួយក្នុងការអនុវត្តកម្មវិធី CSR/RBC ដ៏រឹងមាំ គឺការចំណាយនៅពេលចាប់ផ្តើម។ ក្នុងនាមជាក្រុមហ៊ុនបង្កើតថ្មី ក្រុមហ៊ុន ហូមហ្វូត ឌីលីវើរី បានទទួលស្គាល់ថា នៅក្នុងករណីមួយចំនួន ជម្រើសជំនួសឲ្យការប្រើប្រាស់ប្លាស្ទិកមានតម្លៃខ្ពស់ជាង ១០ដង។ លើសពីនេះទៀត វត្ថុធាតុដើមសរីរាង្គមានតំលៃថ្លៃ។[៤១] រោងចក្រកាត់ដេរក៏បានសម្តែងនូវអារម្មណ៍ថាកម្មវិធី CSR ត្រូវបានគេមើលឃើញថា ជាការងារដែលចំណាយច្រើនបំផុត។[៤២] ទាក់ទងនឹងការចំណាយជាក់ស្តែងសម្រាប់សិប្បករអង្គរត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន៦០.០០០ដុល្លារ ជារៀងរាល់ឆ្នាំ សម្រាប់វគ្គបណ្តុះបណ្តាលឧបករណ៍ប្រាក់រង្វាន់បុគ្គលិក និងការធានារ៉ាប់រងឯកជន។[៤៣] ចំពោះក្រុមហ៊ុន ម្រុំធម្មជាតិ SPLE មានការចំណាយពី ៣០០ ទៅ ៤០០ដុល្លារ ក្នុង១ខែ លើការជួលផ្ទះ និងថ្លៃបាយសម្រាប់បុគ្គលិក។[៤៤] រីឯរោងចក្រកាត់ដេរវិញ ទោះបីជាមិនមានការប្រកាសពី ចំណាយជាក់ស្តែងការបណ្តុះបណ្តាលទៅលើវគ្គអក្ខរកម្ម និងសុខភាពមានការចំណាយទាបបំផុត ដោយសារតែរោងចក្រនេះបានសហការជាមួយអ្នកស្ម័គ្រចិត្ត និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួន។[៤៥] ហាងអាហារ Eleven One Kitchen បានប៉ាន់ប្រមាណថាតម្លៃនៃការវេចខ្ចប់លក្ខណៈជីវម៉ាសអាចចំណាយប្រហែល១០០ដុល្លារ ក្នុងមួយខែ ហើយតម្លៃបន្លែសរីរាង្គជាធម្មតាត្រូវចំណាយទ្វេដងនៃតម្លៃ បន្លែមិនមែនសរីរាង្គ។ ជាទូទៅ ហាងអាហារ Eleven One Kitchen បានមើលឃើញថាការចំណាយមានតំលៃថ្លៃបើធៀបទៅនឹងផលិតផលអសរីរាង្គ និងទំនិញប៉ះពាល់ដល់បរិស្ថានដទៃទៀត។[៤៦] ក្រុមហ៊ុនអេមរុរាយស៍ ប៉ាន់ប្រមាណថាក្រុមហ៊ុនចំណាយលើសកម្មភាពសហគមន៍អស់ ៤០.០០០ដុល្លារជារៀងរាល់ឆ្នាំហើយសកម្មភាពដទៃទៀតដែលជួយដល់កសិករគឺប្រហែល ១២០.០០០ដុល្លារ ជារៀងរាល់ឆ្នាំ (មិនគិតបញ្ចូលការចំណាយលើម៉ាស៊ីន)។[៤៧] នេះបានន័យថាក្រុមហ៊ុនអេមរុរាយស៍ មិនទាន់ទទួលបានផលចំណេញប្រចាំឆ្នាំច្រើននៅឡើយទេ យ៉ាងណាមិញក្រុមហ៊ុននេះផ្តោតសំខាន់លើ ចីរភាពជាងការចំណេញរយៈពេលខ្លី ដូចនេះពួកគេសម្លឹងមើលទៅការចំណេញរយៈពេលវែង។[៤៨] សហគ្រាសលាងឡេង ក៏បានទទួលស្គាល់ថាកម្មវិធី CSR របស់គេចំណាយប្រាក់ និងពេលវេលាច្រើន។[៤៩] បញ្ហាប្រឈមមួយទៀតសម្រាប់អាជីវកម្ម គឺបុគ្គលិកខ្វះការយល់ដឹងអំពី មូលហេតុក៏ដូចជាតម្លៃ និងអត្ថប្រយោជន៍នៃការអនុវត្តកម្មវិធីនេះ។ សម្រាប់បុគ្គលិកអ្នកគ្រប់គ្រងហើយពេលខ្លះដៃគូអាជីវកម្មរបស់ក្រុមហ៊ុន Golden SMEs សិប្បករអង្គរ រោងចក្រកាត់ដេរ និងហូមហ្វូតឌីលីវើរី មិនយល់ពីការចាំបាច់របស់ក្រុមហ៊ុនក្នុងការអនុវត្តសកម្មភាពទាំងនេះទេ។ ឧទាហរណ៍ពីដំបូងឡើយបុគ្គលិកកម្មកររបស់សិប្បករអង្គរមិនយល់ពីតម្លៃនៃលំហាត់ប្រាណនៅកន្លែងធ្វើការឡើយ។[៥០] ចំណែកឯបុគ្គលិកនៅក្រុមហ៊ុន Golden SMEs វិញ ដំបូងមិនយល់ច្បាស់ពីមូលហេតុនៃការបរិច្ចាគឈាមឬការសម្អាតឆ្នេរឡើយ។[៥១] រីឯអតិថិជន និងបុគ្គលិកហាងអាហារ Eleven One Kitchen ដើមឡើយមិនយល់ពីអត្ថប្រយោជន៍នៃសកម្មភាពទាំងនេះទេហើយ

ចោទសួរម្ចាស់ហាងថា ហេតុអ្វីចាំបាច់ចំណាយជាច្រើនទៅលើការប្រើប្រាស់បំពង់បឺតឬស្សី បើភាគច្រើនគេយល់ថាបំពង់បឺតឬស្សីនេះមិនមានអនាម័យដូចជាបំពង់បឺតផ្លាស្ទិកទេ។[៥២]

## ១២. ភាពជាដៃគូ

ដូចផ្នែកផ្សេងៗទៀតនៅក្នុងអាជីវកម្ម ដៃគូសហការក៏មានសារៈសំខាន់សម្រាប់ភាពជោគជ័យផងដែរ។ ការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការស្ម័គ្រចិត្តបង្កើនលទ្ធភាពអាជីវកម្មក្នុងការទទួលបានអ្នកជំនាញនិងការគាំទ្រផ្សេងទៀតដោយចំណាយតិច/មិនចំណាយថវិកាឡើយ។ ជាឧទាហរណ៍ រោងចក្រកាត់ដេរបានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយនៅក្នុងស្រុក ដើម្បីទទួលបានវគ្គបណ្តុះបណ្តាលផ្នែកអប់រំ និងសុខភាព។[៥៣]

ហាងអាហារ Eleven One Kitchen បានសហការជាមួយក្រុមហ៊ុន Plastic Free Cambodia ដើម្បីទទួលបានគន្លឹះក្នុងការបណ្តុះបណ្តាលបុគ្គលិកអំពីការកែច្នៃវត្ថុឡើងវិញ ហើយអង្គការមិត្តសម្លាញ់ (Friends International) ក៏បានជួយក្នុងការបញ្ជូនបុគ្គលិកមកផងដែរ។[៥៤] ចំណែកឯសិប្បករអង្គរវិញបានសហការណ៍ជាមួយអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) ក្នុងការផ្តល់ជាកម្មវិធីចំណេះដឹង និងវិជ្ជាជីវៈសម្រាប់យុវជន ហើយក៏បានផ្តល់ឱកាសដល់សិស្ស៤ រូបមកហាត់រៀននៅសិប្បករអង្គរផងដែរ។ ក្នុងឆ្នាំ២០១២ សិប្បករអង្គរបានផ្តល់ជាក្រម៉ា និងឯកសណ្ឋានសម្រាប់សាលា Salai Bai ដែលបណ្តុះបណ្តាលយុវជន និងជនអសមត្ថភាពលើផ្នែកបដិសណ្ឋារកិច្ចដោយឥតគិតថ្លៃ។ [៥៥] មិនតែប៉ុណ្ណោះសិប្បករអង្គរក៏បានសហការជាមួយសមាគម Sipar ដោយទទួលបានការបង្ហាញអំពីអក្សរសាស្រ្តនៅចំការសូត្រអង្គរ (Angkor Silk Farm) និងការនិទានរឿងសម្រាប់បុគ្គលិកសិប្បករអង្គរ និងកូនៗរបស់ពួកគេនៅរោងជាងផ្សេងៗទៀត។[៥៦] ការសហការនេះមិនត្រឹមតែជួយគាំទ្រដល់សហគមន៍ដែលក្រុមហ៊ុនបានធ្វើប្រតិបត្តិការជាមួយនោះទេ តែក៏ផ្តល់នូវវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកផងដែរ។

ភាពជាដៃគូសហការជាផ្នែកសំខាន់សម្រាប់ក្រុមហ៊ុន អេមរុរាយស៍ ព្រោះក្រុមហ៊ុន អេមរុរាយស៍ចាត់ទុកការធ្វើការជាមួយកសិករក្នុងនាមជា "ដៃគូសហការ" ជាជាងអ្នកផ្គត់ផ្គង់។ លើសពីនេះទៅទៀតក្រុមហ៊ុន អេមរុរាយស៍ បានសហការដៃគូជាមួយស្ថាប័នសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation) ក្នុងគម្រោងអង្ករចីរភាពដោយលើកកម្ពស់ផលិតកម្មអាហារឲ្យមានចីរភាព អាចតាមដានបាន និងជួយបរិស្ថាន។ ដើម្បីតាមដានពីផលិតផលនៃសង្វាក់ផលិតកម្មរបស់គេ ក្រុមហ៊ុនអេមរុរាយស៍ក៏បានសហការជាមួយគម្រោងប្លុករាយស៍ (BlocRice) ក្រុមហ៊ុនសាណូរាយស៍ (SanoRice) និងអង្គការអុកស្វាមកម្ពុជា។[៥៧]

## ១៣. អត្ថប្រយោជន៍ពីការវិនិយោគ

ជាទូទៅ ក្រុមហ៊ុនឃើញថាការវិនិយោគពេលវេលា និងប្រាក់លើកម្មវិធី CSR នឹងទទួលបានផលមកវិញ។ ទាំងនេះអាចរាប់បញ្ចូលនូវកេរ្តិ៍ឈ្មោះល្អជាងមុននៅក្នុងសង្គម ហើយពួកគេអាចដំណើរការឬបង្កើតទំនុកចិត្ត និងទំនាក់ទំនងល្អៗជាងមុនជាមួយបុគ្គលិក។ ក្រុមហ៊ុនរកឃើញថា ការវិនិយោគលើបុគ្គលិកអាចបង្កើតបរិយាកាសការងារល្អជាងមុន និងអាចរក្សាបុគ្គលិកបានយូរ។ សម្រាប់ក្រុមហ៊ុន Golden SMEs ការមានកម្មវិធី CSR បន្ថយការចាកចេញរបស់បុគ្គលិក ហើយបង្កើនទំនុកចិត្តនៅក្នុងក្រុមហ៊ុនជាងមុន។[៥៨] លោក Jack van Dokkum មានប្រសាសន៍ថា៖ "ការចំណាយប្រាក់លើសកម្មភាព CSR គឺជាការវិនិយោគមួយ ដែលលទ្ធផលមិនងាយនឹងតាមដានភ្លាមៗទេ ហើយជាធម្មតាអត្ថប្រយោជន៍គឺផ្តល់ដោយប្រយោល។ អត្ថប្រយោជន៍ធំបំផុតចំពោះក្រុមហ៊ុន គឺភាពស្មោះត្រង់ និងទំនុកចិត្តរបស់បុគ្គលិកមកលើក្រុមហ៊ុន។ នៅពេលក្រុមហ៊ុនចាប់ផ្តើមប្រាស្រ័យទាក់ទងជាមួយបុគ្គលិក ហើយយល់អំពីរបៀបដែលពួកគេមើលឃើញពីក្រុមហ៊ុន ថាតើអ្វីទៅជាគំនិត និងការរំពឹងទុករបស់ពួកគេនឹងជួយឲ្យក្រុមហ៊ុនជ្រើសរើសយកវិធីត្រឹមត្រូវដើម្បីរក្សាបុគ្គលិកបានយូរ ហើយក្រុមហ៊ុននឹងទទួលបានការទុកចិត្តពីពួកគេ។ គាត់បន្តថា៖ ការមានកម្មវិធី CSR នាំឲ្យលទ្ធផលអនុវត្តការងារជារួមប្រសើរឡើង។"[៥៩] យោងតាមឯកឧត្តមលោក ភៀក សុខ ដែលជាប្រធានកម្មវិធីនៅមជ្ឈមណ្ឌលបង្ការគ្រោះមហន្តរាយអាស៊ី (Asian Disaster Preparedness Center) មានប្រសាសន៍ថា "ការចូលរួមចំណែកបរិច្ចាគប្រាក់ចំណេញរបស់យើងទៅសង្គមនឹង ទទួលបានការគាំទ្រការជឿទុកចិត្ត និងកេរ្តិ៍ឈ្មោះពីអតិថិជន និងដៃគូដែលជាវិធីសាស្ត្រធ្វើឲ្យមាននិរន្តរភាពអាជីវកម្ម"។[៦០] សិប្បកអង្គរ បានទទួលស្គាល់ថាគោលនយោបាយ CSR ពួកគេបានជួយកាត់បន្ថយជម្ងឺ ហើយបុគ្គលិកមានកម្លាំងជាងមុន។ សិប្បករអង្គរមានកម្រិតបុគ្គលិកចាកចេញតិចខ្លាំងណាស់ (តិចជាងមួយភាគរយ) និងរកឃើញថាបុគ្គលិកមានការលះបង់ខ្ពស់ចំពោះក្រុមហ៊ុនព្រោះពួកគេយល់ឃើញថាក្រុមហ៊ុនបានយកចិត្តទុកដាក់ និងការពារពួកគេពីការចំណាកស្រុកទៅទីក្រុងឬប្រទេសផ្សេងៗ។[៦១]

ចំណែកឯសហគ្រាស លាងឡេង វិញបរិយាកាស CSR នៅក្នុងក្រុមហ៊ុនបានជួយកាត់បន្ថយការចំណាយក្នុងរយៈពេលវែង ដោយបង្វែរពីកាកសំណល់ទៅជាផលិតផលផ្សេងៗ និងដោយការកាត់បន្ថយការប្រើប្រាស់ និងចំណាយលើថ្លៃអគ្គិសនី។ លោក លាង ឡេង បានប៉ាន់ស្មានលើការសន្សំសំចៃពីការប្រើប្រាស់អគ្គិសនី និងទឹកដោយគាត់អាចសន្សំបានពី ៧,០០០ ទៅ៨,០០០ ដុល្លាររៀងរាល់ឆ្នាំ។[៦២]

ជាទូទៅការវិនិយោគក្នុងកម្មវិធី CSR អាចនាំមកនូវកេរ្តិ៍ឈ្មោះល្អដល់ក្រុមហ៊ុននៅក្នុងសហគមន៍។ យោងទៅតាម ក្រុមហ៊ុន ហូមហ្វូតឌីលីវើរី កម្មវិធី CSR បានធ្វើឲ្យពួកគេមានទំនុកចិត្ត និងបង្កើនកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនហើយក៏ទាក់ទាញអ្នកវិនិយោគផងដែរ។ នៅពេលដែលអ្នកផ្គត់ផ្គង់និងដៃគូសហការផ្តោតសំខាន់ទៅលើគុណភាព និងការបែងចែកប្រាក់ចំណេញពួកគេក៏ផ្តល់នូវតម្លៃសមរម្យ ហើយធានាឲ្យបាននូវពេលវេលាជាក់លាក់ក្នុងការដឹកជញ្ជូន។[៦៣] ក្នុងនាមជាអាជីវកម្មដែលទើបបង្កើតថ្មី និងកំពុងតែរីកចម្រើន អត្ថប្រយោជន៍នៃកេរ្តិ៍ឈ្មោះបានផ្តល់ឱកាសឲ្យក្រុមហ៊ុនមានការប្រកួតប្រជែងស្របច្បាប់ដែលអាចទាក់ទាញអតិថិជន និងធ្វើឲ្យអាជីវកម្មកាន់តែប្រសើរឡើង។ បច្ចុប្បន្នហាងអាហារ Eleven One Kitchen ត្រូវបានគេស្គាល់ថាជាអាជីវកម្មដែលមិនផ្តល់ផលប៉ះពាល់ដល់បរិស្ថាន ដូច្នេះហើយអាជីវកម្មរបស់ពួកគេមានការរីកចម្រើនខ្លាំងដោយមានស្ថាប័នធំៗចង់ឲ្យហាងពួកគេរៀបចំកម្មវិធីជូន។[៦៤]សហគ្រាសលាងឡេងក៏ទទួលស្គាល់ដែលថាកេរ្តិ៍ឈ្មោះល្អរបស់ពួកគាត់នៅក្នុងសង្គមបានធ្វើឲ្យអ្នកដទៃស្គាល់ និងចង់ទិញផលិតផលរបស់ពួកគាត់។[៦៥]

ហាងអាហារ Eleven One Kitchen បានឃើញថាការវិនិយោគលើ CSR ទទួលបានផលត្រឡប់មកវិញច្រើន ដូចជាយើងមិនមានអារម្មណ៍ខុសឆ្គងលើការប្រើប្រាស់ប្លាស្ទិក ព្រោះក្នុងអាជីវកម្មនេះមិនបានប្រើប្រាស់ប្លាស្ទិកឡើយ ហើយឃើញថាវាមានអត្ថប្រយោជន៍ចំពោះបរិស្ថាន ព្រមទាំងសុខភាពរបស់អតិថិជនផងដែរ។[៦៦] លើសពីនេះទៅទៀតហាងអាហារ Eleven One Kitchen កត់សម្គាល់ថាភោជនីយដ្ឋានមួយចំនួនដែលនៅជិតនោះបានចាប់ផ្តើមប្រើប្រាស់សម្ភារៈដោយគ្មានសារធាតុគីមីក្នុងការវេចខ្ចប់។[៦៧]

ក្រុមហ៊ុន អេមរុាយស៍ ប្រហែលជាមិនទាន់ឃើញពីផលត្រលប់ពីការវិនិយោគលើកម្មវិធី CSR ទេ ប៉ុន្តែនៅឆ្នាំ២០១៨ ក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ាន (The ASEAN Business Advisory Council) បានជ្រើសរើសក្រុមហ៊ុន អេមរុាយស៍ ជាម្ចាស់ពានរង្វាន់ Golden Agrow ដែលទទួលស្គាល់ពីសមិទ្ធផលរបស់ក្រុមហ៊ុនដែលជាម្ចាស់ជើងឯកក្នុងការរួមចំណែកដ៏អស្ចារ្យដល់វិស័យកសិកម្ម។[៦៨]

## ១៤. សេចក្តីសន្និដ្ឋាន/អនុសាសន៍ និងវិធីសាស្ត្រសម្រាប់ក្រុមហ៊ុន ក្នុងការចាប់ផ្តើមកម្មវិធីនេះ

អាជីវកម្មដែលបង្ហាញនៅក្នុងករណីសិក្សានេះមានចំណុចដូចគ្នាមួយគឺ CSR programme របស់ពួកគេបានបង្កប់យ៉ាងជ្រៅក្នុងចក្ខុវិស័យ និងបេសកកម្មរបស់ក្រុមហ៊ុន។ ជារឿយៗ វាជាចក្ខុវិស័យរបស់ស្ថាបនិកក្រុមហ៊ុនដែលផ្តោតលើការបង្កើតអាជីវកម្មមួយដែលផ្តល់ផលជាវិជ្ជមានដល់សង្គម។ ក្រុមហ៊ុនមានវិធីសាស្ត្រផ្សេងៗគ្នាក្នុងគោលបំណងនេះ ពេលខ្លះតាមរយៈការផ្តល់សិទ្ធិដល់និយោជិកឬសុខភាព និងសុខុមាលភាព ឬផលប៉ះពាល់ដល់បរិស្ថានទាប ឬការអភិវឌ្ឍសហគមន៍ដែលក្រុមហ៊ុនកំពុងមានប្រតិបត្តិការ។ មនុស្សភាគច្រើនបានយល់ស្របថាមានការចំណាយប្រាក់និងពេលវេលាច្រើនទៅលើកម្មវិធី CSR ប៉ុន្តែផលដែលទទួលបានពីការវិនិយោគនេះគឺខ្ពស់ ទាក់ទងនឹងកេរ្តិ៍ឈ្មោះ ផលពីការសន្សំពីការចំណាយរយៈពេលវែង និងចំណេះដឹងអាជីវកម្មរបស់ពួកគេដែលផ្តល់ផលវិជ្ជមានដល់សង្គម ដែលជាមូលហេតុក្នុងការលើកទឹកចិត្តឲ្យក្រុមហ៊ុនបន្តរួមចំណែក និងបង្កើតកម្មវិធី CSR របស់ពួកគេ។ សារដ៏សំខាន់មួយទៀតដែលបានបង្ហាញដោយក្រុមហ៊ុន គឺតួនាទីជាវិជ្ជមាននៃភាពជាដៃគូក្នុងកម្មវិធី CSR ។ ជារឿយៗ ភាពជាដៃគូបានអនុញ្ញាតឲ្យក្រុមហ៊ុនពង្រីក និងកសាងកម្មវិធី CSR ឬផ្តល់ឲ្យពួកគេនូវជំនាញដែលមានតម្លៃពីខាងក្រៅ (ឧទាហរណ៍៖ ការបណ្តុះបណ្តាល។

ឯកឧត្តម គឿន សុខ បានផ្តល់អនុសាសន៍ថាគួរមានការអប់រំបន្ថែម និងការលើកកម្ពស់ការយល់ដឹងអំពី អ្វីទៅជា CSR ហើយវាអាចផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ជំនួញរបស់ពួកគេ។[៦៩] លោក ចំរើន មកពីក្រុមហ៊ុន ហូមហ្វូតឌីលីវើរី បានលើកទឹកចិត្តឲ្យអ្នកជំនួញមានឆន្ទៈខ្ពស់ ប៉ុន្តែត្រូវចាប់ផ្តើមពីតូចបន្តិចម្តងៗដើម្បីឲ្យជំនួញរបស់ពួកគេរីកលូតលាស់ប្រកបដោយចីរភាព។ "នៅពេលដែលអាជីវកម្មដំណើរការ នោះសហគមន៍នឹងផ្តល់ផលត្រលប់មកវិញ"។[៧០]

> **"នៅពេលដែលអាជីវកម្មដំណើរការ នោះសហគមន៍នឹងផ្តល់ផលត្រលប់មកវិញ"**
> លោក រិច ចំរើន, ស្ថាបនិក ហូមហ្វូតឌីលីវើរី

អនុសាសន៍សម្រាប់សហគ្រាសធុនតូច និងមធ្យមពីលទ្ធផលនៃករណីសិក្សាមានដូចខាងក្រោម៖

- ចាប់ផ្តើមពីចក្ខុវិស័យនៅក្នុងអាជីវកម្មរបស់អ្នក ហើយកំណត់អាទិភាព CRS និងគោលបំណងរបស់អ្នក
- ត្រួតពិនិត្យមើលក្របខណ្ឌច្បាប់ក្នុងលក្ខខណ្ឌការចុះបញ្ជីអាជីវកម្ម ការអនុលោមតាមពន្ធ និងការអនុលោមតាមច្បាប់ការងាររបស់កម្ពុជា
- ពិនិត្យលើបទដ្ឋានឧស្សាហកម្ម ដើម្បីលើកកម្ពស់ការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវ (RBC) របស់អ្នកទៅតាមបទដ្ឋានអន្តរជាតិ។ (មើលប្រភពបន្ថែម)
- អនុវត្តប្រព័ន្ធប្រឆាំងអំពើពុករលួយ ដូចជាប្រព័ន្ធសុចរិតភាពសាជីវកម្មរបស់អង្គការតម្លាភាពកម្ពុជា។ (មើលប្រភពបន្ថែម)
- ចាត់ចែងថវិកាសម្រាប់កម្មវិធី CSR និងកំណត់អាទិភាពសម្រាប់ការងារកម្មវិធីរបស់អ្នក ហើយអ្នកត្រូវមានបេសកកម្មច្បាស់លាស់ និងអាទិភាព ពីព្រោះវាគឺជាចំណុចចាំបាច់សម្រាប់កម្មវិធី CSR ដើម្បីទទួលបានជោគជ័យ។
- ស្វែងរកដៃគូដែលអាចជួយបំពេញថវិកា ឬជំនាញរបស់អ្នក។ ស្វែងរកអង្គការមិនមែនរដ្ឋាភិបាលដែលមានជំនាញក្នុងកម្មវិធីបណ្តុះបណ្តាល ឬចីរភាពនៃបរិស្ថាន អាស្រ័យលើអាទិភាពរបស់អ្នក។
- តាមដាន និងទទួលយកមតិយោបល់លើកម្មវិធី CSR របស់អ្នក និងធ្វើការផ្លាស់ប្តូរ ហើយអភិវឌ្ឍតាមតម្រូវការ។

**ប្រភពបន្ថែម៖**

Better Factories Cambodia: **https://betterwork.org/where-we-work/cambodia/**

TI Cambodia's Business Integrity Programme: **ticambodia.org**

Plastic Free Cambodia: **https://plasticfreecambodia.com/**

SHE Investments, Business Information Platform:
**http://ngeayngeay.co/business-registration/limited-company-cambodia/**

# ឯកសារយោង

[១]Cheng Sokhorng, “Ministry changes SME data,” The Phnom Penh Post, 27 February 2018, https://www.phnompenhpost.com/business/ministry-changes-sme-data.

[២]MIME Mission, 2010.

[៣]MIME Mission, 2010.

[៤]MIME, 2009

[៥]OECD, Policy Framework for Investment User´s Toolkit, 2011, available here: https://www.oecd.org/investment/toolkit/policyareas/responsiblebusinessconduct/

[៦]“Understanding Cambodian Small and Medium Enterprise Needs for financial Services and Products”, Cambodia Agribusiness Series-No.2

[៧]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហៀ អ៊ារៀស នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៨]ការធ្វើបទសម្ភាសន៍ជាមួយសិប្បកអង្គរដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[៩]Artisans Angkor Website, accessed on 4 Nov 2018, http://www.artisansdangkor.com/beliefs-mission-statement.php

[១០]ការធ្វើបទសម្ភាសន៍តាមទូរសព្ទជាមួយលោក សុង សារ៉ន អគ្គនាយកក្រុមហ៊ុនអេមរុរាយស៍ដោយកញ្ញាសរ សាន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

[១១]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន Golden SMEs ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា

[១២]ការធ្វើបទសម្ភាសន៍ជាមួយលោកលាង ឡេង ដោយកញ្ញាសរ សាន នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[១៣]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញាសរ សាន លោកស្រី សូហៀ អ៊ារៀស និងកញ្ញាសួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[១៤]ការធ្វើបទសម្ភាសន៍ជាមួយម្រុំធម្មជាតិ SPLE ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[១៥]SPLE Moringa Website, accessed on 4 Nov. 2018, https://www.splemoringa.com/

[១៦]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[១៧]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ដោយកញ្ញាសរ សាន នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[១៨]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[១៩]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[២០]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញាសរ សាន លោកស្រី សូហ្វៀ អ៊ារៀស និងកញ្ញាសួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[២១]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន Golden SMEs ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា

[២២]ការធ្វើបទសម្ភាសន៍ជាមួយម្រុំធម្មជាតិ SPLE ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា និងការធ្វើបទសម្ភាសន៍ជាមួយ ហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហ្វៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[២៣]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន Golden SMEs ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា និងការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញា សរ សាន លោកស្រី សូហ្វៀ អ៊ារៀស និងកញ្ញា សួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[២៤]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[២៥]ការធ្វើបទសម្ភាសន៍ជាមួយម្រុំធម្មជាតិ SPLE ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[២៦]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ដោយកញ្ញាសរ សាន នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា.

[២៧]ក្រមការងាររបស់កម្ពុជា ឆ្នាំ១៩៩៧ លេខ ២៣៨-២៤០

[២៨]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញាសរ សាន លោកស្រី សូហ្វៀ អ៊ារៀស និងកញ្ញាសួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[២៩]ការធ្វើបទសម្ភាសន៍តាមទូរសព្ទជាមួយលោក សុង សារ៉ន អគ្គនាយកក្រុមហ៊ុនអេមរុរាយស៍ដោយកញ្ញា សរ សាន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

[៣០]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហ្វៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៣១]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហ្វៀ អ៊ារៀស នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៣២]ការធ្វើបទសម្ភាសន៍ជាមួយលោកលាង ឡេង ដោយកញ្ញាសរ សាន នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

# ឯកសារយោង

[៣៣]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ដោយកញ្ញាសរ សាន នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៣៤]ការធ្វើបទសម្ភាសន៍តាមទូរសព្ទជាមួយលោក សុង សារ៉ែន អគ្គនាយកក្រុមហ៊ុនអេមរុរាយស៍ដោយកញ្ញា សរ សាន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

[៣៥]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញាសរ សាន លោកស្រី សូហ្វៀ អ៊ារៀស និងកញ្ញា សួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៣៦]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[៣៧]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន Golden SMEs ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា

[៣៨]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ដោយកញ្ញាសរ សាន នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៣៩]ការធ្វើបទសម្ភាសន៍ជាមួយលោកលាង ឡេង ដោយកញ្ញាសរ សាន នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៤០]ការធ្វើបទសម្ភាសន៍តាមទូរសព្ទជាមួយលោក សុង សារ៉ែន អគ្គនាយកក្រុមហ៊ុនអេមរុរាយស៍ដោយកញ្ញា សរ សាន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

[៤១]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ដោយកញ្ញាសរ សាន នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៤២]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញា សរ សាន លោកស្រីសូហ្វៀ អ៊ារៀស និងកញ្ញា សួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៤៣]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញា សរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[៤៤]ការធ្វើបទសម្ភាសន៍ជាមួយម្រុំធម្មជាតិ SPLE ដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[៤៥]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញា សរ សាន លោកស្រី សូហ្វៀ អ៊ារៀស និងកញ្ញា សួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៤៦]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហ្វៀ អ៊ារៀស នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៤៧]ការធ្វើបទសម្ភាសន៍តាមទូរសព្ទជាមួយលោក សុង សារ៉ែន អគ្គនាយកក្រុមហ៊ុនអេមរុរាយស៍ដោយកញ្ញា សរ សាន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

[៤៨]ការធ្វើបទសម្ភាសន៍តាមទូរសព្ទជាមួយលោក សុង សារ៉ន អគ្គនាយកក្រុមហ៊ុនអេមរុរាយស៍ដោយកញ្ញា សរ សាន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

[៤៩]ការធ្វើបទសម្ភាសន៍ជាមួយលោក លាង ឡេង ដោយកញ្ញា សរ សាន នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៥០]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញា សរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[៥១]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន Golden SMEs ដោយកញ្ញា សរ សាន និងសួន ម៉ារីណា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា

[៥២]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហ្វៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៥៣]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញាសរ សាន លោកស្រី សូហ្វៀ អ៊ារៀស និងកញ្ញា សួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៥៤]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហ្វៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៥៥]Artisans Angkor Website, http://www.artisansdangkor.com/people-15-88-artisans-angkores-partnerships-with-ngos.php, accessed 7 Nov. 2018.

[៥៦]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[៥៧]"Amru Rice: Be Sustainable & Responsible and Lead the Change," The Khmer Times, 24 May 2018, https://www.khmertimeskh.com/50493094/amru-rice-be-sustainable-responsible-and-lead-the-change/.

[៥៨]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន Golden SMEs ដោយកញ្ញា សរ សាន និងសួន ម៉ារីណា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា

[៥៩]ការធ្វើបទសម្ភាសន៍ជាមួយលោក Jack van Dokkum ដោយកញ្ញា សរ សាន លោកស្រី សូហ្វៀ អ៊ារៀស និងកញ្ញា សួន ម៉ារីណា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៦០]ការធ្វើបទសម្ភាសន៍ជាមួយឯកឧត្តម គៀក សុខ ដោយកញ្ញា សរ សាន នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៦១]ការធ្វើបទសម្ភាសន៍ជាមួយសិប្បករអង្គរដោយកញ្ញាសរ សាន និងសួន ម៉ារីណា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ខេត្តសៀមរាប ប្រទេសកម្ពុជា

[៦២]ការធ្វើបទសម្ភាសន៍ជាមួយលោកលាង ឡេង ដោយកញ្ញាសរ សាន នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

# ឯកសារយោង

[៦៣]ការធ្វើបទសម្ភាសន៍ជាមួយលោកលាង ឡេង ដោយកញ្ញាសរ សាន នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៦៤]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៦៥]ការធ្វើបទសម្ភាសន៍ជាមួយលោកលាង ឡេង ដោយកញ្ញាសរ សាន នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៦៦]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៦៧]ការធ្វើបទសម្ភាសន៍ជាមួយហាងអាហារ Eleven One Kitchen ដោយលោកស្រី សូហៀ អ៊ារៀសនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៦៨]Sok Chan, "Amru Rice chosen for Asean award," The Khmer Times, 11 Sep. 2018, https://www.khmertimeskh.com/50532326/amru-rice-chosen-for-asean-award.

[៦៩]ការធ្វើបទសម្ភាសន៍ជាមួយឯកឧត្តម ភឿក សុខ ដោយកញ្ញា សរ សាន នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

[៧០]ការធ្វើបទសម្ភាសន៍ជាមួយក្រុមហ៊ុន ហូមហ្វូតឌីលីវើរី ដោយកញ្ញា សរ សាន នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

**អង្គការតម្លាភាពកម្ពុជា**
ផ្ទះលេខ ១៣ ផ្លូវលេខ ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក,
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា, ១២១៥១
គេហទំព័រក្នុងប្រទេស: www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្ដាល: www.transparency.org